សាលាឧទ្ធរណ៍

សំណុំរឿងព្រហ្មទណ្ឌ

លេខ: ៥០៣

ចុះថ្ងៃទី០៦-០៦-២០១៣

**សាលដីកា**

លេខ: ៤៨ "ក្រ ॥ សវ"

ចុះថ្ងៃទី២៥-០៦-២០១៤

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

## តាមនាមប្រជារាស្ត្រខ្មែរ

## សាលាឧទ្ធរណ៍ភ្នំពេញ

បង្កើតឡើងតាមច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃតុលាការ... 

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជម្រះក្តីដែលប្រកាសឲ្យប្រើតាមក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី ០៨ ខែកុម្ភៈ ឆ្នាំ១៩៩៣ បានបើកសវនាការជាសាធារណៈនៅសាលសវនាការសាលាឧទ្ធរណ៍ នាថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ២០១៤ ដោយមានសមាសភាពដូចខាងក្រោមៈ

**<u>សមាសភាពក្រុមប្រឹក្សា</u>**

-ឯកឧត្តម [redacted] ប្រធាន

-លោក [redacted] ចៅក្រមប្រឹក្សា

-លោក [redacted] ចៅក្រមប្រឹក្សា

**<u>តំណាងមហាអយ្យការ</u>**

ឯកឧត្តម [redacted] អគ្គព្រះរាជអាជ្ញារង

**<u>ក្រឡាបញ្ជីសវនាការ</u>**

លោកស្រី [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នៃរឿងព្រហ្មទណ្ឌលេខ ៥០៣ ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៣ ដែលមានៈ

-ជនជាប់ចោទឈ្មោះ [redacted] ប៊ុណ្ណារិទ្ធិ ហៅ ហ៊ា ភេទប្រុស អាយុ ១៩ឆ្នាំ ជាតិខ្មែរ ជានីតិជន ទីកន្លែងកំណើត[redacted] ទីលំនៅបច្ចុប្បន្នភូមិ [redacted] ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) នៅលីវ ទោសពីមុនគ្មាន ឃុំខ្លួនថ្ងៃទី ២១ ខែកុម្ភៈ ឆ្នាំ២០១២។

-ជនជាប់ចោទឈ្មោះ [redacted] ទីសំណាង ហៅ ទី ភេទប្រុស អាយុ ៣០ឆ្នាំ ជាតិខ្មែរ មុខរបរមិនពិតប្រាកដ កើតនៅ[redacted] ទីលំនៅសព្វថ្ងៃភូមិ[redacted] ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) ប្រពន្ធឈ្មោះ [redacted] មានកូន ១នាក់ ទោសពីមុនគ្មាន ឃុំខ្លួនថ្ងៃទី ១០ ខែឧសភា ឆ្នាំ២០១២។

-ជនជាប់ចោទឈ្មោះ [redacted] វណ្ណា ហៅ ខ្នា ភេទប្រុស អាយុ ៣២ឆ្នាំ ជាតិខ្មែរ មុខរបរកសិករ ទីកន្លែងកំណើតភូមិ[redacted] កើត និងទីលំនៅបច្ចុប្បន្ន [redacted] ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (ស) ប្រពន្ធឈ្មោះ [redacted] (រ) មានកូន ៣នាក់ ទោសពីមុនគ្មាន គេចខ្លួន។

ជាប់ចោទពីបទៈ លួចដោយមានស្ថានទម្ងន់ទោសដោយការប្រព្រឹត្តអំពើហិង្សា (កាច់សោរម៉ូតូ) ប្រព្រឹត្តនៅភូមិ កំពង់ត្រាចទី ១ ឃុំកំពង់ត្រាចខាងកើត ស្រុកកំពង់ត្រាច ខេត្តកំពត កាលពីថ្ងៃទី ០៧ ខែវិច្ឆិកា ឆ្នាំ២០១១ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឲ្យផ្តន្ទាទោសតាមមាត្រា ៣៥៧ និងមាត្រា ៤០០ នៃក្រមព្រហ្ម ទណ្ឌ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ភេទប្រុស កើតឆ្នាំ ១៩៩៤ ជាតិខ្មែរ មុខរបរសិស្ស ថ្នាក់ទី១២ ទីលំនៅបច្ចុប្បន្នភូមិ [redacted]។

## ការប្រព្រឹត្តរបស់ជនជាប់ចោទមានដូចតទៅៈ

កាលពីថ្ងៃទី ០៧ ខែវិច្ឆិកា ឆ្នាំ២០១១ វេលាម៉ោង ១០និង ៣០នាទី មានបទល្មើសប្រព្រឹត្តនៅចំណុច សាលារៀនចិនភាសាចិនគៀនយូន នៅភូមិកំពង់ត្រាចទី ១ ឃុំកំពង់ត្រាចខាងកើត ស្រុកកំពង់ត្រាច ខេត្តកំពត មានករណីលួចដោយមានស្ថានទម្ងន់ទោសការប្រព្រឹត្តហិង្សា (កាច់សោរម៉ូតូ) ប្រព្រឹត្តដោយជនសង្ស័យចំនួនពីរនាក់ ឈ្មោះ [redacted] ប៊ុណ្ណារិទ្ធិ ហៅ ហ៉ាវ និងឈ្មោះ [redacted] ទីសំណាង ហៅ ទី បានធ្វើសកម្មភាព នាំគ្នាកាច់សោរម៉ូតូរបស់ឈ្មោះ [redacted] សុភាព ភេទស្រី អាយុ ១៦ឆ្នាំ ម៉ូតូដែលយកបានមានម៉ាកសេ ១២៥ សេរី ២០១១ ពណ៌ខ្មៅមួយគ្រឿង លេខតួលេខម៉ាស៊ីន ៨៥៣៩៩៤៧ ដោយម្ចាស់ម៉ូតូបានទុកនៅក្រៅ ហើយចូលបណ្ណាល័យ។

បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ១០ ឃ ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១៣ របស់សាលាដំបូងខេត្តកំពត ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅៈ

១-ផ្តន្ទាទោសលើៈ

ក-ឈ្មោះ [redacted] ប៊ុណ្ណារិទ្ធិ ហៅ ហ៉ាវ ភេទប្រុស អាយុ ១៩ឆ្នាំ ជាតិខ្មែរ មុខរបរនិស្សិត កើតនៅភូមិ [redacted] ទីលំនៅសព្វថ្ងៃភូមិ [redacted] ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) នៅលីវ ទោសពីមុនគ្មាន។ ឈ្មោះ [redacted] ទីសំណាង ហៅ ទី ភេទប្រុស អាយុ ៣០ឆ្នាំ ជាតិខ្មែរ មុខរបរមិនពិតប្រាកដ កើតនៅ [redacted] ទីលំនៅសព្វថ្ងៃភូមិ [redacted] ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) ប្រពន្ធឈ្មោះ [redacted] មានកូន ១នាក់ ទោសពីមុនគ្មាន។

ដាក់ពន្ធនាគារក្នុងម្នាក់ៗកំណត់រយៈពេល ០៣(បី)ឆ្នាំ ពីបទ លួចមានស្ថានទម្ងន់ទោសដោយការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅភូមិកំពងត្រាចទី ១ ឃុំកំពង់ត្រាចខាងកើត ស្រុកកំពង់ត្រាច ខេត្តកំពត កាលពីថ្ងៃទី ០៧ ខែវិច្ឆិកា ឆ្នាំ២០១១ ។ ប្រព្រឹត្តនៅភូមិ១ឧសភា សង្កាត់កំពង់កណ្តាល ក្រុងកំពត ខេត្តកំពត កាលពីថ្ងៃទី ២៦ ខែសីហា ឆ្នាំ២០១១។ប្រព្រឹត្តនៅភូមិ១ឧសភា សង្កាត់កំពង់កណ្តាល ក្រុងកំពតកណ្តាល ក្រុងកំពត ខេត្តកំពត កាលពីថ្ងៃទី ០៣ ខែកញ្ញា ឆ្នាំ២០១១ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឲ្យផ្តន្ទាទោសតាម មាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។

ខ-ឈ្មោះ [redacted] វណ្ណា ហៅ ខ្លា ភេទប្រុស អាយុ ៣២ឆ្នាំ ជាតិខ្មែរ មុខរបរ កសិករ ទីកន្លែងកំណើត [redacted] ទីលំនៅបច្ចុប្បន្ន [redacted] ឪពុកឈ្មោះ [redacted] (រ) ម្ដាយឈ្មោះ [redacted] (ស) ប្រពន្ធឈ្មោះ [redacted] (រ) មានកូន ៣នាក់ ទោសពីមុនគ្មាន។

ដាក់ពន្ធនាគារកំណត់រយៈពេល ០២ (ពីរ)ឆ្នាំ ពីបទ ទទួលផលចោរកម្ម ប្រព្រឹត្តនៅភូមិកំពង់ត្រាចទី ១ ឃុំកំពង់ត្រាច ខាងកើត ស្រុកកំពង់ត្រាច ខេត្តកំពត កាលពីថ្ងៃទី ០៧ ខែវិច្ឆិកា ឆ្នាំ២០១១ និងប្រព្រឹត្តនៅភូមិ១ឧសភា សង្កាត់កំពង់កណ្ដាល ក្រុងកំពត ខេត្តកំពត កាលពីថ្ងៃទី ០៣ ខែកញ្ញា ឆ្នាំ២០១១ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្ដន្ទាទោសតាមមាត្រា ៤០០ នៃក្រមព្រហ្មទណ្ឌ។

២-អោយឈ្មោះ [redacted] ប៊ុណ្ណារិទ្ធិ ហៅ ហ័រ , [redacted] ទីសំណាង និងឈ្មោះ [redacted] វណ្ណា ដែលមានសាវតាជាតិដូចខាងលើ រួមគ្នាសងសំណងជម្ងឺចិត្តជាប្រាក់ទៅឲ្យឈ្មោះ [redacted] សុភាព ចំនួន ១៧៥០ (មួយពាន់ប្រាំពីររយហាសិប) ដុល្លាអាមេរិក និងឈ្មោះ [redacted] សុភ័ក្រ្ត ចំនួន ១៧២០ (មួយពាន់ប្រាំពីររយម្ភៃ) ដុល្លាអាមេរិក ឲ្យឈ្មោះ [redacted] ប៊ុណ្ណារិទ្ធិ និងឈ្មោះ [redacted] ទីសំណាង រួមគ្នាសងសំណងជម្ងឺចិត្តជាប្រាក់ទៅឲ្យឈ្មោះ [redacted] សាម៉ន ចំនួន ៤,៥០០,០០០ (បួនលានប្រាំសែន)រៀល។ សំណើរលើសពីនេះបដិសេធចោល។

៣-បង្គាប់ឲ្យចាប់ឃុំខ្លួនឈ្មោះ [redacted] វណ្ណា ដែលមានសាវតាជាតិដូចខាងលើចាប់ពីថ្ងៃប្រកាសសាលក្រមនេះតទៅ។

៤-សាលក្រមនេះជំនុំជំរះ និងប្រកាសជាសាធារណៈ ចំពោះមុខដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុភាព និងជនជាប់ចោទឈ្មោះ [redacted] ប៊ុណ្ណារិទ្ធិ និងកំបាំងមុខដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] សាម៉ន, [redacted] សុភ័ក្រ្ត និងជនជាប់ចោទឈ្មោះ [redacted] វណ្ណា ឈ្មោះ [redacted] ទីសំណាង បើកផ្លូវប្តឹងទាស់ និងឧទ្ធរណ៍តាមកំណត់ច្បាប់។

-បានឃើញ សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍។

-បានឃើញ របាយការណ៍រឿងព្រហ្មទណ្ឌរបស់ចៅក្រមរបាយការណ៍ សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍។

**<u>នាពេលសវនាការ</u>**

-ជនជាប់ចោទឈ្មោះ [redacted] ប៊ុណ្ណារិទ្ធិ ( វត្តមាន )

-មេធាវីលោក [redacted] ស្រីសួគ៌ ការពារឲ្យជនជាប់ចោទឈ្មោះ [redacted] ប៊ុណ្ណារិទ្ធិ ( វត្តមាន )

-ជនជាប់ចោទឈ្មោះ [redacted] ទីសំណាង (វត្តមាន)

-មេធាវីលោក [redacted] យ៉ូរ៉ាន់ ការពារឲ្យជនជាប់ចោទឈ្មោះ [redacted] ទីសំណាង ( វត្តមាន )

-ដើមបណ្ដឹងឈ្មោះ [redacted] សុភក្រ្ត (អវត្តមាន)

ជនជាប់ចោទឈ្មោះ [redacted] ប៊ុណ្ណារិទ្ធិ បានឆ្លើយថា ខ្លួនមិនសុខចិត្តប្តឹងឧទ្ធរណ៍មកនេះដោយសារខ្លួនមិនបានប្រព្រឹត្តលួចម៉ូតូដូចការចោទប្រកាន់នោះទេ។ ឈ្មោះ [redacted] ប៊ុណ្ណារិទ្ធិ នៅមុខនគរបាល បានឆ្លើយសារភាពនោះដោយសារ គេបង្ខំឲ្យឆ្លើយ ប៉ុន្តែនៅថ្ងៃទី ២៦ ខែសីហា ឆ្នាំ២០១១ ខ្លួននិងឈ្មោះ [redacted] ទីសំណាង បានឆ្លើយសកម្មភាពលួចកាច់សោរម៉ូតូរបស់ជនរងគ្រោះនៅចំណុចសួនច្បារក្នុងភូមិ១ឧសភា នៅថ្ងៃទី ០៣ ខែកញ្ញា ឆ្នាំ២០១១ បានធ្វើសកម្មភាពលួចកាច់សោរម៉ូតូរបស់ជនរងគ្រោះនៅចំណុចហាងការ៉ាអូខេផ្ទះលោក [redacted] ប៊ុណ្ណារិទ្ធិ ក្នុងភូមិ១ឧសភា និងថ្ងៃទី ០៧ ខែវិច្ឆិកា ឆ្នាំ២០១១ បានធ្វើសកម្មភាពលួចកាច់សោរម៉ូតូ របស់ជនរងគ្រោះនៅចំណុចសាលារៀនភាសាចិនគៀនយូន ភូមិកំពង់ត្រាច រួចយកម៉ូតូទៅលាក់ទុកនៅផ្ទះរបស់ឈ្មោះ [redacted] វណ្ណា ។ បន្ទាប់មកពួកខ្លួនយកម៉ូតូទាំងនេះទៅលក់បាន ៦៥០ ដុល្លា ចែកគ្នាចាយ។

សំណូមពរ សុំរួចផុតពីបទចោទ។

-ជនជាប់ចោទឈ្មោះ [redacted] ទីសំណាង បានឆ្លើយថា ខ្លួនទើបតែស្គាល់ឈ្មោះ [redacted] ប៊ុណ្ណារិទ្ធិ បានជាង១ខែប៉ុណ្ណោះហើយដើមបណ្តឹងក៏មិនបានស្គាល់ដែរ ហើយខ្លួនទើបតែប្រព្រឹត្តលើកទី១ ជាមួយឈ្មោះ [redacted] ប៊ុណ្ណារិទ្ធិ។

សំណូមពរ សុំតុលាការលើកលែងចោទប្រកាន់។

-តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍បានធ្វើសេចក្តីសន្និដ្ឋានថាៈការឆ្លើយដោះសាររបស់ជនជាប់ចោទនេះគ្មានមូលដ្ឋានច្បាស់លាស់ទេ តែភស្តុតាងបានបញ្ជាក់គ្រប់គ្រាន់ហើយ ហេតុដូច្នេះសូមក្រុមប្រឹក្សា សម្រេចតាមច្បាប់។

-មេធាវី ការពារឲ្យជនជាប់ចោទឈ្មោះ [redacted] ប៊ុណ្ណារិទ្ធិ បានធ្វើសេចក្តីសន្និដ្ឋានថា ពាក់ព័ន្ធនិងអង្គហេតុទាំងបីកូនក្តីរបស់ខ្លួនពុំបានប្រព្រឹត្តបទល្មើសឡើយ។ ហេតុដែលកូនក្តីខ្លួនឆ្លើយសារភាពនៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌គឺសមត្ថកិច្ចសរសេរហើយឲ្យកូនក្តីខ្លួនផ្តិតមេដៃទាំងការភិតភ័យ។ សំណូមពរសុំឲ្យកូនក្តីខ្លួនរួចផុតពីបទចោទប្រកាន់។

-មេធាវីការពារឲ្យជនជាប់ចោទឈ្មោះ [redacted] ទីសំណាង បានធ្វើសេចក្តីសន្និដ្ឋានថា សូមក្រុមប្រឹក្សាពិចារណាលើភស្តុតាង និងចម្លើយនៅសមត្ថកិច្ចតាមមាត្រា ៣២១ នៃក្រមព្រហ្មទណ្ឌ។

## សភាព្រហ្មទណ្ឌ យល់ឃើញថាៈ

១-បណ្តឹងឧទ្ធរណ៍លេខ ១៨ ចុះថ្ងៃទី ០៦ ខែមិថុនា ឆ្នាំ២០១៣ របស់លោក [redacted] សំលេង ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តកំពតប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ១០ ឃ ចុះថ្ងៃទី ០៦ ខែមីនា ឆ្នាំ២០១៣ របស់សាលាដំបូងខេត្តកំពត ត្រង់ចំណុចផ្តន្ទាទោសស្រាលពេក និងបណ្តឹងឧទ្ធរណ៍លេខ ២៥ ចុះថ្ងៃទី ១៣ ខែមីនា ឆ្នាំ២០១៣ របស់លោក [redacted] ស្រីសួត ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ១០ ឃ ចុះ ថ្ងៃទី ០៦ ខែមិថុនា ឆ្នាំ២០១៣ របស់សាលាដំបូងខេត្តកំពតត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច៖

បានធ្វើឡើងត្រឹមត្រូវក្នុងកំណត់ច្បាប់ សភាព្រហ្មទណ្ឌទទួលជំនុំជម្រះបាន យោងតាមមាត្រា ៣៨១ មាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ទីសំណាង និងឈ្មោះ [redacted] ប៊ុណ្ណារិទ្ធិ បានឆ្លើយប្រហាក់ប្រហែលគ្នាថាពួកខ្លួនមិនបានប្រព្រឹត្តអំពើលួចម៉ូតូរបស់ជនរងគ្រោះដូចការចោទប្រកាន់នោះទេ។ប៉ុន្តែតាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ប៊ុណ្ណារិទ្ធិ នៅមុខនគរបាលយុត្តិធម៌បានឆ្លើយថា កាលពីថ្ងៃទី ២៦ ខែសីហា ឆ្នាំ២០១១ ខ្លួននិងឈ្មោះ [redacted] ទីសំណាង បានធ្វើសកម្មភាពលួចកាច់សោរម៉ូតូរបស់ជនរងគ្រោះនៅចំណុចសួនច្បារឆ្នាំ២០០០ ក្នុងភូមិ១ឧសភា នៅថ្ងៃទី ០៣ ខែកញ្ញា ឆ្នាំ២០១១ បានធ្វើសកម្មភាព លួចកាច់សោរម៉ូតូរបស់ជនរងគ្រោះនៅចំណុចហាងការ៉ាអូខេផ្ទះលោក [redacted] ប៊ុណ្ណារិទ្ធិ ក្នុងភូមិ១ឧសភា និងនៅថ្ងៃទី ០៧ ខែវិច្ឆិកា ឆ្នាំ២០១១ បានធ្វើសកម្មភាពលួចកាច់សោរម៉ូតូរបស់ជនរងគ្រោះនៅចំណុចសាលារៀនភាសាចិនគៀនយូន ភូមិកំពង់ក្រាច រួចយកម៉ូតូដែលលួចបាននេះទៅលាក់ទុកនៅផ្ទះរបស់ឈ្មោះ [redacted] វណ្ណា។ បន្ទាប់មកក៏យកម៉ូតូទាំងនេះលក់យកលុយចែកគ្នាចាយ ដែលជាទម្រង់មួយនៃអំពើរួមគំនិតប្រព្រឹត្តអំពើលួចដោយការកាប់គាស់ទម្លុះទម្លាយ បំពានមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ ដូចមានសព្វគ្រប់ក្នុងផ្នែកសំអាងហេតុនៃសាលក្រមព្រហ្មទណ្ឌលេខ ១០ ឃ ចុះថ្ងៃទី ០៦ ខែមីនា ឆ្នាំ២០១៣ របស់សាលាដំបូងខេត្តកំពតបញ្ជាក់ស្រាប់។

៣-ជនជាប់ចោទបានឆ្លើយបដិសេធចម្លើយរបស់ខ្លួននៅមុខនគរបាល ដោយលើកមូលហេតុថាកម្លាំងនគរបាលគម្រាមកំហែងនិងវាយតំខ្លួនបង្ខំឲ្យខ្លួនឆ្លើយ តែចម្លើយនេះតុលាការមិនអាចជឿ និងមិនអាចពិចារណាបានឡើយពីព្រោះគ្រាន់តែជាចម្លើយផ្ទាល់មាត់ប៉ុណ្ណោះពុំមានសាក្សីឬភស្តុតាងណាបញ្ជាក់ឲ្យបានច្បាស់លាស់សោះឡើយ។

៤-សាលក្រមព្រហ្មទណ្ឌលេខ ១០ ឃ ចុះថ្ងៃទី ០៦ ខែមីនា ឆ្នាំ២០១៣ របស់សាលាដំបូងខេត្តកំពត ដែលសម្រេចសេចក្តីមកនេះមានលក្ខណៈត្រឹមត្រូវតាមច្បាប់ហើយ គួរសភាព្រហ្មទណ្ឌតម្កល់ទុកជាបានការតាមច្បាប់។

## **<u>ហេតុដូច្នេះ វិនិច្ឆ័យសេចក្តី</u>**

១-ទទួលបណ្តឹងឧទ្ធរណ៍លេខ ១៨ ចុះថ្ងៃទី ០៦ ខែមិថុនា ឆ្នាំ២០១៣ របស់ឈ្មោះ [redacted] សំលេងព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តកំពត និងបណ្តឹងឧទ្ធរណ៍លេខ ២៥ ចុះថ្ងៃទី ១៣ ខែមីនា ឆ្នាំ២០១៣ របស់ឈ្មោះ [redacted] ស្រីសួគ៌ មេធាវីការពារជនជាប់ចោទ ទុកជាត្រឹមត្រូវតាមទម្រង់ តែបដិសេធចោលដោយទាស់គតិច្បាប់។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ១០ ឃ ចុះថ្ងៃទី ០៦ ខែមីនា ឆ្នាំ២០១៣ របស់សាលាដំបូងខេត្តកំពតទុកជាបានការ។

៣-បន្តឃុំខ្លួនជនជាប់ចោទឈ្មោះ [redacted] ប៊ុណ្ណារិទ្ធិ និងឈ្មោះ [redacted] ទីសំណាង តាមនីតិវិធីច្បាប់។/

៤-សាលដីកានេះជំនុំជម្រះកាលពីថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ២០១៤ និងប្រកាសជាសាធារណៈថ្ងៃទី ២៥ ខែមិថុនា ឆ្នាំ២០១៤ កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណីចំពោះមុខជនជាប់ចោទ។

បើកសិទ្ធិប្តឹងតវ៉ាក្នុងកំណត់ច្បាប់។

សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកាស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់គ្រប់តំណែង និងកងកំលាំងប្រដាប់អាវុធជួយសហការណ៍ អនុវត្តសាលដីកានេះអោយបានសម្រេច ប្រសិនបើមានសំណូមពរត្រឹមត្រូវតាមច្បាប់។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សា |
|---|---|---|
| ហត្ថលេខា:[redacted] | ហត្ថលេខា:[redacted], [redacted] | ហត្ថលេខា:[redacted] |

---

បានឃើញ

ប្រធានសាលាឧទ្ធរណ៍

[redacted]

បានចំលងត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ,ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១៤

ក្រឡាបញ្ជី

[redacted]